GMAC
Garment Manufacturers Association in Cambodia

# សេចក្តីប្រកាសព័ត៌មាន

## ការកើនឡើងប្រាក់ឈ្នួលតម្រូវឲ្យមានវិធានការរឹងមាំលើផលិតភាព

ការកើនឡើងប្រាក់ឈ្នួលក្នុងរយៈកាល៥ឆ្នាំចុងក្រោយនេះកំពុងជំរុញឲ្យមានវិធានការរឹងមាំលើការកែលម្អផលិតភាពនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងកម្ពុជា។ ខណៈវាជាវិធីមួយក្នុងចំណោមវិធីផ្សេងៗក្នុងការទ្រទ្រង់និងរក្សាភាពប្រកួតប្រជែង រាជរដ្ឋាភិបាលនិងសមាគមរោងចក្រកាត់ដេរនៅកម្ពុជាកំពុងរៀបចំវេទិកាកែលម្អផលិតភាពក្នុងអំឡុងពិព័រណ៍ការងារនិងផលិតភាពជាតិឆ្នាំ២០១៧ ដែលនឹងប្រារព្ធធ្វើឡើងនៅថ្ងៃទី២៧-២៨ ខែតុលា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ។ វេទិកានិងពិព័រណ៍នេះគឺដើម្បីបង្កើនការយល់ដឹងឲ្យបានខ្លាំងជាងមុនអំពីប្រធានបទផលិតភាពនៅក្នុងឧស្សាហកម្មនេះនិងក្នុងចំណោមសាធារណជនទូទៅ។ នេះបើតាមលោក John Cha ប្រធានគណៈកម្មាធិការរៀបចំកម្មវិធីរបស់សមាគម ដែលបានលើកឡើង។

ប្រាក់ឈ្នួលនឹងកើនឡើងនាឆ្នាំខាងមុខ ដូច្នេះកម្រិតផលិតភាពគួរតែកើនឡើងផងដែរដើម្បីធានានូវការរស់រាននៃសហគ្រាសនានាខណៈយើងកំពុងឆ្ពោះទៅរកការសម្រេចឲ្យបាននូវតម្លៃបន្ថែមខ្ពស់ជាងមុន។

នៅវេទិកានេះ អ្នកជំនាញខាងផលិតភាពមកពីប្រទេសជប៉ុន កូរ៉េ ឥណ្ឌា និងម៉ាឡេស៊ី នឹងត្រូវបានអញ្ជើញឲ្យចូលរួមដើម្បីចែករំលែកបទពិសោធន៍របស់ពួកគេក្នុងការអភិវឌ្ឍផលិតភាព និងការអនុវត្តល្អបំផុតដែលនឹងមានអត្ថប្រយោជន៍យ៉ាងខ្លាំងសម្រាប់កម្ពុជា។ អ្នកជំនាញនឹងចែករំលែកផងដែរអំពីបទពិសោធន៍ក្នុងបច្ចេកទេសជាក់លាក់អំពី Lean ដូចជា Line Balancing, Value Stream Mapping និង Quick Changeover ។

ការប្រកួតប្រជែងពាក់ព័ន្ធនឹងផលិតភាពក៏ត្រូវបានរៀបចំឡើងផងដែរ និងមានការចូលរួមពីរោងចក្រសមាជិកមួយចំនួនរបស់សមាគម។ ពានរង្វាន់សម្រាប់កម្មករ-និយោជិតឆ្នើម និង ពានរង្វាន់ខាយហ្សិន/ការអនុវត្ត ៥S (ដែលជាវិធីសាស្ត្ររបស់ជប៉ុនសម្រាប់ការកែលម្អជានិច្ច ដែលនាំឲ្យមានផលិតភាពប្រសើរឡើង)ត្រូវបានរៀបចំឡើងផងដែរ។ រដ្ឋមន្ត្រីក្រសួងការងារនឹងចូលរួមជាអធិបតីក្នុងពិធីប្រគល់រង្វាន់។ ការចូលរួមពិព័រណ៍និងវេទិកានេះគឺមិនគិតថ្លៃ ហើយរដ្ឋាភិបាលនិងសមាគមរំពឹងថានឹងមានការចូលរួមនិងទស្សនាច្រើនកុះករ។

វេទិកាផលិតភាពនៅពិព័រណ៍ការងារ និងផលិតភាពជាតិឆ្នាំ២០១៧គឺជាវេទិកាទីមួយក្នុងប្រទេសកម្ពុជា ហើយជាជំហាននិងការចាប់ផ្តើមដែលមានប្រយោជន៍និងក្នុងទិសដៅត្រឹមត្រូវ។

ភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

**សមាគមរោងចក្រកាត់ដេរនៅកម្ពុជា**

តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Trapeang Kul Village, Sangkat Kantouk, Khan Por Sen Chey, Phnom Penh Cambodia.
Tel: (855) 23-88 34 35 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org